ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៨៨១ / ៣០-០៩-២០១៣

**សាលដីកា**

លេខ ១៩ "ក្រ.III.ច" / ២២-០៤-២០១៤

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ ភ្នំពេញ**

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ០២-០៤-២០១៤ ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៨៨១ ចុះថ្ងៃទី ៣០-៩-២០១៣ ដោយមាន៖

**១-ជនជាប់ចោទឈ្មោះ** [redacted] ចំរើន ភេទប្រុស អាយុ ៣១ឆ្នាំ សញ្ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" នៅលីវ ។ ឃុំខ្លួនលេខ: ៨៥៣ ត.ព្រ ចុះថ្ងៃទី ២៩ ខែមិនា ឆ្នាំ២០១៣

-មានមេធាវីការពារសិទ្ធិលោក [redacted] ឌិមុល ។

ជាប់ចោទពីបទ: រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅភូមិអណ្តូង៦

សង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃខែសីហា ឆ្នាំ២០១២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើ ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**២-ដើមបណ្តឹង**រដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៣៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted]។

-ជនរងគ្រោះឈ្មោះ [redacted] ស្រីណា ភេទស្រី អាយុ ១៤ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅផ្ទះលេខ [redacted]

-មានមេធាវីការពារលោក [redacted] **ណារ៉ា** , [redacted] សូនី ។

## ៦រឿងហេតុមានដូចតទៅ៖

កាលពីថ្ងៃទីមិនចាំ ខែសីហា ឆ្នាំ២០១២ វេលាម៉ោងប្រហែល ៥ ទាបភ្លឺ ស្ថិតនៅភូមិអណ្តូង៦ សង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានការរួមភេទជាមួយក្មេងស្រីអាយុ ១៤ឆ្នាំ ដែលបង្កឡើងដោយឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ ៣១ឆ្នាំ ទៅលើ ក្មួយស្រីបង្កើតរបស់ខ្លួនឈ្មោះ [redacted] ស្រីណា ភេទស្រី អាយុ ១៤ឆ្នាំ នៅពេលដែលឈ្មោះ [redacted] ស្រីណា កំពុងដេក ហើយឈ្មោះ [redacted] ចំរើន បានឡើងចាប់សម្រាតសំលៀកបំពាក់របស់ ឈ្មោះ [redacted] ស្រីណា រួចអោបថើប និងបានយកប្រដាប់ភេទរបស់ខ្លួនដាក់ទៅក្នុងប្រដាប់ភេទ របស់ [redacted] ស្រីណា រហូតបានសម្រេច។ ឈ្មោះ [redacted] ចំរើន រួមភេទបានសម្រេចជាច្រើនដងជា មួយឈ្មោះ [redacted] ស្រីណា លុះដល់ពេលម្តាយរបស់ឈ្មោះ [redacted] ស្រីណា ត្រឡប់ពីធ្វើការ នៅប្រទេសម៉ាឡេស៊ីវិញ ទើបដឹងរឿងពីអ្នកជិតខាងប្រាប់ ហើយម្តាយរបស់ជនរងគ្រោះ ឈ្មោះ [redacted] ស៊ីផុន ដាក់ពាក្យបណ្តឹងតែម្តង។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ: ៦៧ ក្រ៦ "ក" ចុះថ្ងៃទី ១៩-៧-២០១៣របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តីថា ៖

-ផ្តន្ទាទោសឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ ៣១ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ៧ (ប្រាំពីរ) ឆ្នាំ ពីបទ: រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅភូមិអណ្តូង៦ សង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃខែសីហា ឆ្នាំ២០១២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើ ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៦-៦-២០១៣ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់។

បានឃើញពាក្យបណ្ដឹងឧទ្ធរណ៍លេខ៥៥៧ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ចំរើន ប្ដឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ៦៧ ក្រ៦ "ភ" ចុះថ្ងៃទី ១៩-៧-២០១៣ ត្រង់សេចក្ដីសម្រេចទាំងមូល របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

### ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង

-ជនជាប់ចោទឈ្មោះ [redacted] **ចំរើន** ថា ខ្លួននិងក្មួយស្រីរបស់ខ្លួនពិតជាមានការស្រលាញ់គ្នា ខ្លួនមិនមានការចាប់បង្ខំទេ មានការរួមភេទជាច្រើនដងមកហើយ ពេលខ្លួនរស់នៅជាមួយនាង ៗ ប្រាប់ថាមានអាយុពី ១៣ឆ្នាំ ទៅ ១៤ឆ្នាំ ។ សុំបន្ធូរបន្ថយទោស ។

-ជនរងគ្រោះឈ្មោះ [redacted] **ស្រីណា** ថា ខ្លួនមិនបានស្រលាញ់គាត់ទេ គាត់ចាប់បង្ខំខ្លួនរួមភេទបានចំនួន ៩ដង ពេលគាត់រួមភេទជាមួយខ្លួនៗមានអាយុទើបតែ១៣ឆ្នាំ ។

### មេធាវីការពារឱ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសេចក្ដីសន្និដ្ឋាន

ជនជាប់ចោទពិតជាបានរួមភេទជាមួយកូនក្ដីខ្លួន ដែលមានអាយុក្រោម១៥ឆ្នាំ តាមការសារភាពនៅពេលសវនាការ មានសំបុត្រកំណើតបញ្ជាក់ទើបតែអាយុ ១៣ឆ្នាំ ។ សុំតម្កល់សាលក្រមទុកជាបានការ ។

### តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន

ជនជាប់ចោទបានឆ្លើយសារភាពនូវការប្រព្រឹត្តរបស់ខ្លួន ។ សុំតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការ ។

### មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋាន

ជនជាប់ចោទបានឆ្លើយសារភាពនូវការប្រព្រឹត្តរបស់ខ្លួន បើពិនិត្យទៅលើសំណុំរឿងជនរងគ្រោះ និងជនជាប់ចោទពិតជាស្រលាញ់គ្នា មានឯកសារសំបុត្រស្នេហារវាងគ្នាទៅវិញទៅមក ជនរងគ្រោះមានអាយុក្រោម១៥ឆ្នាំ តែរូបរាងមាំទាំ សុំបន្ធូរបន្ថយតាមមាត្រា ៩៣ , ៩៤ នៃក្រមព្រហ្មទណ្ឌ ។

## តុលាការថយទៅពិភាក្សា

ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ។

ក្រោយពីបានស្ដាប់ជនជាប់ចោទឆ្លើយ និងសំណូមពរ។

ក្រោយពីបានស្ដាប់តំណាងមហាអយ្យការធ្វើសន្និដ្ឋាន។

ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសន្និដ្ឋាន។

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ។

## សាលាឧទ្ធរណ៍

## យល់ឃើញថា:

១-បណ្តឹងឧទ្ធរណ៍លេខ ៥៥៧ ចុះថ្ងៃទី ០៨.០៨.២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] **ចំរើន** ប្តឹងនិងសាលក្រមព្រហ្មទណ្ឌលេខ ៦៧ ក្រ៦ "ភ" ចុះថ្ងៃទី ១៩-០៧-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តាមចម្លើយជនជាប់ចោទនៅពេលសវនាការបានសារភាពថា ខ្លួនពិតជាបានរួមភេទជាមួយជនរងគ្រោះមែន តែមិនមានការចាប់បង្ខំទេ ជនជាប់ចោទក៏បានបញ្ជាក់ថាជនរងគ្រោះត្រូវជាក្មួយ តែដោយការស្រលាញ់គ្នា ពេលដែលខ្លួនរស់នៅជាមួយ ជនរងគ្រោះក៏បានប្រាប់ថានាងមានអាយុទើបតែ ១៣ឆ្នាំ ទៅ ១៤ឆ្នាំ ដែរ។

៣-ពិនិត្យទៅលើឯកសារសំណុំរឿងមានភស្តុតាងសំបុត្រស្នេហាទៅវិញទៅមក ទោះបីមានការស័គ្រចិត្តពីជនរងគ្រោះក៏ដោយ តាមផ្លូវច្បាប់មាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើ ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការរួមភេទជាមួយជនរងគ្រោះជាអនីតិជនអាយុក្រោម ១៥ឆ្នាំ ត្រូវតែមានទោស ហើយនាពេលសវនាការជនរងគ្រោះថាជនជាប់ចោទបង្ខំខ្លួនរួមភេទ ។

៤-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចំរើន ពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅភូមិអណ្តូង៦ សង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃខែសីហា ឆ្នាំ២០១២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើ ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៥-សាលក្រមព្រហ្មទណ្ឌលេខ ៦៧ ក្រ៦ "ភ" ចុះថ្ងៃទី ១៩.០៧.២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ហើយ គប្បីសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ ដដែល ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥៥៧ ចុះថ្ងៃទី ០៨.០៨.២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] **ចំរើន** ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៧ ក្រ៦ "ភ" ចុះថ្ងៃទី ១៩.០៧.២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤-សាលដីការនេះជំនុំជំរះជាសាធារណៈថ្ងៃទី ០២.០៤.២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២២.០៤.២០១៤ ចំពោះមុខជនជាប់ចោទ ជនរងគ្រោះ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] . [redacted] | ហត្ថលេខា: [redacted] |

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី...16... ខែ...6.....ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]